សុខភាព និងជីវិត
កាន់តែប្រសើរ

# ផ្តល់ក្តីស្រលាញ់ ចំពោះកូនតាមរយៈ ការធានារ៉ាប់រងការអប់រំ



## AIA សម្រាប់កូន

ការបានក្លាយជាឪពុកម្តាយគឺជាការបើកទំព័រថ្មីមួយដ៏មានអត្ថន័យក្នុងជីវិតព្រមទាំងជាពេលវេលានិងបទពិសោធន៍ដ៏រីករាយបំផុត។ ពេលវេលានេះទាមទារឱ្យយើងជាឪពុកម្តាយ ចាប់ផ្តើមគិតគូកាន់តែច្បាស់ ផ្តល់ការយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវខ្ពស់ ពោលគឺធានាថាកូនតូចៗជាទីស្រឡាញ់របស់អ្នក ទទួលបានអ្វីៗគ្រប់យ៉ាងស្របតាមតម្រូវការរបស់ពួកគេ មានការលូតលាស់ធំធាត់ល្អ មានសុខភាពល្អ និងមានអនាគតដ៏ត្រចះត្រចង់។ ការទទួលបានការអប់រំល្អ គឺជាអាទិភាពដំបូង និងចាំបាច់ ដែលឪពុកម្តាយទាំងអស់ប្រាថ្នាចង់ផ្តល់ឱ្យកូនៗរបស់ខ្លួនឱ្យល្អ
បំផុតតាមដែលអាចធ្វើបាន។

ការអប់រំ ជាអំណោយដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន។ ចាប់ផ្តើមរៀបចំ គម្រោងផែនការសន្សំឥឡូវនេះ

# AIA សម្រាប់កូន



## តើ AIA សម្រាប់កូនជាអ្វី?

**AIA** សម្រាប់កូន ជាគម្រោងសន្សំដែលផ្តល់ការធានាកញ្ចប់ហិរញ្ញវត្ថុបម្រុងលើការសិក្សារបស់កូនអ្នក នៅថ្នាក់ឧត្តមសិក្សា ហើយជាចំនែកមួយដ៏សំខាន់ជួយសម្រួលក្នុងការរស់នៅ និងជាពិសេសផ្តល់ជូននូវការការពារផ្នែកហិរញ្ញវត្ថុ សម្រាប់កូនជាទីស្រឡាញ់របស់អ្នក ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើងដោយនឹកស្មានមិនដល់ចំពោះអ្នក។

**គម្រោងនេះផ្តល់ជូនជាមួយនឹងអត្ថប្រយោជន៍ពិសេសគួរឱ្យទាក់ទាញ៖**

- **អត្ថប្រយោជន៍លើការសិក្សា** សម្រាប់បង់ថ្លៃសិក្សារបស់កូនអ្នក ដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា និង **អត្ថប្រយោជន៍បន្ថែមលើការសិក្សា** ជាប្រាក់ជំនួយបន្ថែម ប្រសិនបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងធ្វើឱ្យអ្នក ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍
- **អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា** សម្រាប់អបអរសាទរភាពជោគជ័យ ការបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ
- **អត្ថប្រយោជន៍ការពារ និងការរួចកាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគត** លើករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ កើតមានឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រង
- ភាពបត់បែននៃរយៈពេលនៃការធានារ៉ាប់រងចាប់ពី 15 ទៅ 22 ឆ្នាំជាមួយនឹងជម្រើស 4 (បួន) ផ្សេងគ្នា សម្រាប់រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង 5 ឆ្នាំ 10 ឆ្នាំ 15 ឆ្នាំ និង 18 ឆ្នាំ។

# AIA សម្រាប់កូន

## តើ AIA សម្រាប់កូន ជួយអ្នករៀបចំផែនការអនាគតការសិក្សាដ៏ត្រចះត្រចង់របស់បុត្រធីតាអ្នកបានយ៉ាងដូចម្តេច?

### អត្ថប្រយោជន៍លើការសិក្សា

### 1. អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា

គម្រោងធានារ៉ាប់រងនេះ ផ្តល់**អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា**លើកញ្ចប់ហិរញ្ញវត្ថុបម្រុងលើការសិក្សា សម្រាប់កូនរបស់អ្នកក្នុងការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា បើទោះជាមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងក៏ដោយ។

អ្នកត្រូវបានធានារ៉ាប់រងអាចជ្រើសរើសទទួលយកការទូទាត់អត្ថប្រយោជន៍លើការសិក្សាជា2(ពីរ)ជម្រើសណាមួយដូចខាងក្រោម៖

- ទទួល **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋានជាទឹកប្រាក់សរុប នៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង មុនកាលបរិច្ឆេទដល់កំណត់ **4** (បួន) ឆ្នាំ ឬ
- ទទួល **105%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋានជា **4** (បួន) ដំណាក់កាល ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| ការទូទាត់អត្ថប្រយោជន៍លើការសិក្សា | នៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង | ចំនួនភាគរយនៃទឹកប្រាក់ជាដំណាក់កាល |
|---|---|---|
| ការទូទាត់លើកទី 1 | មុនកាលបរិច្ឆេទដល់កំណត់ 4 ឆ្នាំ | 30% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| ការទូទាត់លើកទី 2 | មុនកាលបរិច្ឆេទដល់កំណត់ 3 ឆ្នាំ | 25% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| ការទូទាត់លើកទី 3 | មុនកាលបរិច្ឆេទដល់កំណត់ 2 ឆ្នាំ | 25% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| ការទូទាត់លើកទី 4 | មុនកាលបរិច្ឆេទដល់កំណត់ 1 ឆ្នាំ | 25% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |

### 2. *អត្ថប្រយោជន៍បន្ថែមលើការសិក្សា

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ទឹកប្រាក់បន្ថែម 100%នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋានសម្រាប់ជម្រើសការទូទាត់សរុប ឬ 105% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋានសម្រាប់ជម្រើសការទូទាត់ជាដំណាក់កាលនៃ**អត្ថប្រយោជន៍លើការសិក្សា** នឹងត្រូវបង់ជូនជាប្រាក់ឧបត្ថម្ភបន្ថែមក្នុងកំឡុងពេលមានគ្រោះអកុសលណាមួយកើតឡើងចំពោះអ្នក។ ចំនួនទឹកប្រាក់បន្ថែមនេះ នឹងត្រូវបង់រួមជាមួយអត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា ហើយក្លាយជា**អត្ថប្រយោជន៍លើការសិក្សាទ្វេដង**សម្រាប់អ្នក ក្នុងការជួយសម្រាលបន្ថែមលើតម្រូវការ ហិរញ្ញវត្ថុផ្សេងទៀតរបស់គ្រួសារ។

* **អត្ថប្រយោជន៍បន្ថែមលើការសិក្សា** នឹងអាចអនុវត្តបានតែចំពោះអ្នកត្រូវបានធានារ៉ាប់រងដែលមាន អាយុចាប់ពី 18 ឆ្នាំឡើងខណៈពេលចុះឈ្មោះដំបូង ហើយអត្ថប្រយោជន៍នេះនឹងត្រូវបង់ជូនប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ មុនពេលទទួលបានការទូទាត់អត្ថប្រយោជន៍លើការសិក្សា (សម្រាប់ជម្រើសនៃការទទួលទឹកប្រាក់សរុប) ឬមុនពេលទទួលបានការទូទាត់លើកទីមួយ (សម្រាប់ជម្រើសនៃការទទួលទឹកប្រាក់ជាដំណាក់កាល)។

# AIA សម្រាប់កូន

## អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា

**អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា**ដើម្បីអបអរសាទរភាពជោគជ័យលើការបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ ជាមួយការផ្តល់ជូនអត្ថប្រយោជន៍ **3** (ដង)៖ **2%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវផ្តល់ជូននៅពេលដែលកូនរបស់អ្នកបញ្ចប់**ថ្នាក់អនុវិទ្យាល័យ** **2%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវផ្តល់ជូនសម្រាប់ការបញ្ចប់**ថ្នាក់វិទ្យាល័យ** និង **6%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវផ្តល់ជូនជាការអបអរសាទរការបញ្ចប់ការសិក្សាពី**សាកលវិទ្យាល័យ**។

| នៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា |
| --- | --- |
| មុនកាលបរិច្ឆេទដល់កំណត់ 7 ឆ្នាំ | 2% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| មុនកាលបរិច្ឆេទដល់កំណត់ 4 ឆ្នាំ | 2% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| នៅកាលបរិច្ឆេទដល់កំណត់ | 6% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |

## អត្ថប្រយោជន៍លើមរណភាព

គម្រោងធានារ៉ាប់រងនេះ ផ្តល់ជូនទឹកប្រាក់ធានារ៉ាប់រងក្នុងករណីមរណភាព រហូតដល់ **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នៅពេលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយអ្វីកាន់តែពិសេស AIA នឹងរ៉ាប់រងទទួលបន្ទុកបង់បុព្វលាភធានារ៉ាប់រងជំនួសបន្តនាពេលអនាគត ដើម្បីជួយសម្រាលបន្ទុក ផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារមួយចំនួន ខណៈ**អត្ថប្រយោជន៍លើការសិក្សា** និង**អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា** នឹងនៅតែបន្តផ្តល់ជូនទោះក្នុងករណីណាក៏ដោយ។

## អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

គម្រោងធានារ៉ាប់រងនេះ ផ្តល់ជូនទឹកប្រាក់ធានារ៉ាប់រងក្នុងករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ រហូតដល់ **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន ហើយអ្វីកាន់តែពិសេស AIA នឹងរ៉ាប់រងទទួលបន្ទុកបង់បុព្វលាភធានារ៉ាប់រងជំនួសបន្តនាពេលអនាគតក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលពិការភាព
ទាំងស្រុង និងជាអចិន្ត្រៃយ៍ ខណៈ**អត្ថប្រយោជន៍លើការសិក្សា** និង**អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា**នឹងនៅតែបន្តផ្តល់ជូនទោះក្នុងករណីណាក៏ដោយ។បន្ទាប់ពីទឹកប្រាក់ធានារ៉ាប់រងសម្រាប់**អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**ត្រូវបានទូទាត់រួចហើយ **អត្ថប្រយោជន៍លើមរណភាព** នឹងមិនមានទៀតឡើយ។

# AIA សម្រាប់កូន

## ឧទាហរណ៍ទី 1៖

### គម្រោងសន្សំសម្រាប់ការសិក្សាកូន

**អ្នកស្រី នារី** មានអាយុ 30 ឆ្នាំ បានរៀបការរួច និងមានកូនប្រុសម្នាក់ឈ្មោះ **បញ្ញា** អាយុ 3 ឆ្នាំ ។ អ្នកស្រីមានគម្រោងរៀបចំគោលដៅហិរញ្ញវត្ថុអនាគតរបស់កូនអ្នកស្រីឱ្យបានល្អតាំងពីដំណាក់កាលដំបូង។ ហើយគោលដៅជាចម្បង គឺដើម្បីរៀបចំកញ្ចប់ថវិកាបម្រុងនាពេលអនាគតសម្រាប់ការសិក្សារបស់កូនអ្នកស្រីសម្រាប់ថ្នាក់ឧត្តមសិក្សា និងជាពិសេសគឺធានាថាកូនរបស់អ្នកស្រីនឹងត្រូវបានមើលថែជានិច្ច ហើយនឹងមិនទទួលរងបន្ទុកហិរញ្ញវត្ថុពេលដែលអ្នកស្រីមិននៅក្បែរ។

| គម្រោងធានារ៉ាប់រង | ករណីសុខភាពល្អ និងសុខសប្បាយ | ករណីជួបគ្រោះអកុសល ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ |
|---|---|---|
| អ្នកស្រី នារី បានជ្រើសយកការធានារ៉ាប់រងជាមួយ AIA សម្រាប់កូន<br>• ទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន៖ **US$10,000**<br>• រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង៖ 15 ឆ្នាំ<br>• រយៈពេលនៃការធានារ៉ាប់រង៖ 19 ឆ្នាំ<br>• បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ៖ **US$708**<br>• បុព្វលាភធានារ៉ាប់រងសរុប៖ **US$10,620** | អត្ថប្រយោជន៍សរុប = **US$11,000**<br>• អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា៖ **US$10,000***<br>• អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សាសរុប៖ **US$1,000** | អត្ថប្រយោជន៍សរុប = **US$31,000**<br>• អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖ **US$10,000**<br>• អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា៖ **US$10,000***<br>• អត្ថប្រយោជន៍បន្ថែមលើការសិក្សា៖ **US$10,000***<br>• អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សាសរុប៖ **US$1,000** |

ចំណាយតិចជាង 8,000 រៀលក្នុងមួយថ្ងៃ ផ្តើមគិតគូរពីអនាគតការសិក្សាដ៏ភ្លឺស្វាងរបស់កូនជាទីស្រឡាញ់របស់អ្នក!

** ចំនួននេះត្រូវបានសន្មតថាម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសទទួលយកអត្ថប្រយោជន៍នេះជាទឹកប្រាក់សរុប។ ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រងជ្រើសរើសទទួលយកអត្ថប្រយោជន៍នេះជាដំណាក់កាល នោះអត្ថប្រយោជន៍របស់គាត់មានចំនួន US$10,500។*

# ក្នុងករណី អ្នកស្រី នារី មានសុខភាពល្អ និងសុខសប្បាយរហូតដល់កាលបរិច្ឆេទដល់កំណត់

**អ្នកស្រី នារី** នឹងទទួលបាន**អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា** ដើម្បីអបអរសាទរភាពជោគជ័យលើការបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ នៅពេលបញ្ញារៀនចប់ថ្នាក់អនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យ។ លើសពីនេះទៀត **អ្នកស្រី នារី** នឹងទទួលបាន**អត្ថប្រយោជន៍លើការសិក្សា** សម្រាប់បញ្ញានៅអាយុ 18 ឆ្នាំ ដើម្បីបន្តការទៅថ្នាក់ឧត្តមសិក្សា។

អត្ថប្រយោជន៍សរុបដែលត្រូវបានធានា

## រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់សរុប ស្របតាមអាយុរបស់បញ្ញា




| អត្ថប្រយោជន៍ សរុប | | | | |
|---|---|---|---|---|
| | - | US$200 | US$10,400 | US$11,000 |

អត្ថប្រយោជន៍សរុបដែលត្រូវបានធានា

## រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់ជាដំណាក់កាល ស្របតាមអាយុរបស់បញ្ញា




| អត្ថប្រយោជន៍ សរុប | | | | | | | |
|---|---|---|---|---|---|---|---|
| | - | US$200 | US$3,400 | US$5,900 | US$8,400 | US$10,900 | US$11,500 |

## ក្នុងករណីមានគ្រោះអកុសលកើតឡើងចំពោះ អ្នកស្រី នារី នៅអាយុ 40 ឆ្នាំ

ក្នុងករណី **អ្នកស្រី នារី** ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍នៅអាយុ 40 ឆ្នាំ គ្រួសាររបស់អ្នកស្រី នឹងទទួលបាន ការការពារផ្នែកហិរញ្ញវត្ថុ 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន ជាទឹកប្រាក់សរុបភ្លាមៗ និងមិនតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងពេលអនាគតបន្តទៀតទេ។ **អត្ថប្រយោជន៍បន្ថែមលើការសិក្សា** 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវបានផ្តល់ជូន ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើង មុនពេលការផ្តល់ជូន**អត្ថប្រយោជន៍លើការសិក្សា**លើកដំបូង។

អត្ថប្រយោជន៍ការពារដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់សរុប ស្របតាមអាយុរបស់បញ្ញា

**អាយុ 13**
- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ US$10,000

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$200

**អាយុ 18**
- អត្ថប្រយោជន៍លើការសិក្សា US$10,000
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$200
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$10,000

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$600

| អត្ថប្រយោជន៍ សរុប | US$10,000 | US$10,200 | US$30,400 | US$31,000 |
|---|---|---|---|---|

អត្ថប្រយោជន៍ការពារដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់ជាដំណាក់កាល ស្របតាមអាយុរបស់បញ្ញា

**អាយុ 13**
- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ US$10,000

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$200

**អាយុ 18**
- អត្ថប្រយោជន៍លើការសិក្សា US$3,000
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$200
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$3,000

**អាយុ 19**
- អត្ថប្រយោជន៍លើការសិក្សា US$2,500
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$2,500

**អាយុ 20**
- អត្ថប្រយោជន៍លើការសិក្សា US$2,500
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$2,500

**អាយុ 21**
- អត្ថប្រយោជន៍លើការសិក្សា US$2,500
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$2,500

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$600

| អត្ថប្រយោជន៍ សរុប | US$10,000 | US$10,200 | US$16,400 | US$21,400 | US$26,400 | US$31,400 | US$32,000 |
|---|---|---|---|---|---|---|---|

# AIA សម្រាប់កូន

## ឧទាហរណ៍ទី 2៖

### អំណោយដ៏មានតម្លៃសម្រាប់ចៅជាទីស្រឡាញ់របស់អ្នក

**លោក ឧត្តម** មានអាយុ45ឆ្នាំមានចៅស្រីម្នាក់ឈ្មោះ**មេត្តា** អាយុ 1ខែ ។ លោកមានគម្រោងនឹងផ្តល់អំណោយដ៏មានតម្លៃដល់ចៅស្រីរបស់គាត់ក្នុងឆ្នាំនេះ ដើម្បីផ្តល់គម្រោងធានារ៉ាប់រងលើការសិក្សារបស់នាង ដើម្បីបម្រុងទុកលើការបង់ថ្លៃសិក្សានៅពេល**មេត្តា** បន្តការសិក្សាថ្នាក់សាកលវិទ្យាល័យ។

| គម្រោងធានារ៉ាប់រង | ករណីសុខភាពល្អ និងសុខសប្បាយ | ករណីជួបគ្រោះអកុសល ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ |
|---|---|---|
| លោក ឧត្តម បានជ្រើសយកការធានារ៉ាប់រង ជាមួយ AIA សម្រាប់កូន<br>• ទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន៖ **US$20,000**<br>• រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង៖ **5** ឆ្នាំ<br>• រយៈពេលនៃការធានារ៉ាប់រង៖ **22** ឆ្នាំ<br>• បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ៖ **US$4,302**<br>• បុព្វលាភធានារ៉ាប់រងសរុប៖ **US$21,510** | អត្ថប្រយោជន៍សរុប = **US$22,000**<br>• អត្ថប្រយោជន៍លើការសិក្សាត្រូវបានធានា៖ **US$20,000***<br>• អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សាសរុប៖ **US$2,000** | អត្ថប្រយោជន៍សរុប = **US$62,000**<br>• អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖ **US$20,000**<br>• អត្ថប្រយោជន៍លើការសិក្សាត្រូវបានធានា៖ **US$20,000***<br>• អត្ថប្រយោជន៍បន្ថែមលើការសិក្សា៖ **US$20,000***<br>• អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សាសរុប៖ **US$2,000** |

** ចំនួននេះត្រូវបានសន្មតថាម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសទទួលយកអត្ថប្រយោជន៍នេះជាទឹកប្រាក់សរុប។ ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រងជ្រើសរើសទទួលយកអត្ថប្រយោជន៍នេះជាដំណាក់កាល នោះអត្ថប្រយោជន៍របស់គាត់មានចំនួន US$21,000។*

## ក្នុងករណី លោក ឧត្ដម មានសុខភាពល្អ និងសុខសប្បាយរហូតដល់កាលបរិច្ឆេទដល់កំណត់

**លោក ឧត្ដម** អាចផ្ដល់អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា ជាអំណោយអបអរសាទរការបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ ដល់ចៅស្រី ពេលនាងរៀនចប់ថ្នាក់អនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យ។ លើសពីនេះទៀត **លោក ឧត្ដម** នឹងទទួលបាន **អត្ថប្រយោជន៍លើការសិក្សា** សម្រាប់ចៅស្រីរបស់គាត់ពេលនាងមានអាយុគ្រប់ 18 ឆ្នាំ ដើម្បីបន្តការសិក្សាទៅថ្នាក់ឧត្ដមសិក្សា។

### អត្ថប្រយោជន៍សរុបដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់សរុប ស្របតាមអាយុរបស់មេត្តា

**អាយុ 1ខែ**
-

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$400**

**អាយុ 18**
- អត្ថប្រយោជន៍លើការសិក្សា **US$20,000**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$400**

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$1,200**

| អត្ថប្រយោជន៍ សរុប | - | US$400 | US$20,800 | US$22,000 |
|---|---|---|---|---|

### អត្ថប្រយោជន៍សរុបដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់ជាដំណាក់កាល ស្របតាមអាយុរបស់មេត្តា

**អាយុ 1ខែ**

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$400**

**អាយុ 18**
- អត្ថប្រយោជន៍លើការសិក្សា **US$6,000**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$400**

**អាយុ 19**
- អត្ថប្រយោជន៍លើការសិក្សា **US$5,000**

**អាយុ 20**
- អត្ថប្រយោជន៍លើការសិក្សា **US$5,000**

**អាយុ 21**
- អត្ថប្រយោជន៍លើការសិក្សា **US$5,000**

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា **US$1,200**

| អត្ថប្រយោជន៍ សរុប | - | US$400 | US$6,800 | US$11,800 | US$16,800 | US$21,800 | US$23,000 |
|---|---|---|---|---|---|---|---|

## ក្នុងករណីមានគ្រោះអកុសលកើតឡើងចំពោះ លោក ឧត្តម នៅអាយុ 48 ឆ្នាំ

ក្នុងករណី **លោក ឧត្តម** ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍នៅអាយុ 48ឆ្នាំ គ្រួសាររបស់លោក នឹងទទួលបានការការពារផ្នែកហិរញ្ញវត្ថុ 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវទូទាត់សរុបភ្លាមៗ និងមិនតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតបន្តទៀតទេ។ **អត្ថប្រយោជន៍បន្ថែមលើការសិក្សា** 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន នឹងត្រូវបានផ្តល់ជូន ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើង មុនពេលផ្តល់ជូន**អត្ថប្រយោជន៍លើការសិក្សា**លើកដំបូង។

អត្ថប្រយោជន៍ការពារដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់សរុប ស្របតាមអាយុរបស់មេត្តា

**អាយុ 3**
- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ US$20,000

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$400

**អាយុ 18**
- អត្ថប្រយោជន៍លើការសិក្សា US$20,000
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$400
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$20,000

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$1,200

| អត្ថប្រយោជន៍ សរុប | | | | |
|---|---|---|---|---|
| | US$20,000 | US$20,400 | US$60,800 | US$62,000 |

អត្ថប្រយោជន៍ការពារដែលត្រូវបានធានា

### រូបភាពបង្ហាញពីជម្រើសនៃការទទួលទឹកប្រាក់ជាដំណាក់កាល ស្របតាមអាយុរបស់មេត្តា

**អាយុ 3**
- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ US$20,000

**អាយុ 15**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$400

**អាយុ18**
- អត្ថប្រយោជន៍លើការសិក្សា US$6,000
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$400
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$6,000

**អាយុ 19**
- អត្ថប្រយោជន៍លើការសិក្សា US$5,000
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$5,000

**អាយុ 20**
- អត្ថប្រយោជន៍លើការសិក្សា US$5,000
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$5,000

**អាយុ 21**
- អត្ថប្រយោជន៍លើការសិក្សា US$5,000
- អត្ថប្រយោជន៍បន្ថែមលើការសិក្សា US$5,000

**អាយុ 22**
- អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា US$1,200

| អត្ថប្រយោជន៍ សរុប | | | | | | | |
|---|---|---|---|---|---|---|---|
| | US$20,000 | US$20,400 | US$32,800 | US$42,800 | US$52,800 | US$62,800 | US$64,000 |

# AIA សម្រាប់កូន

## ព័ត៌មានសង្ខេបស្តីពីផលិតផល

## អត្ថប្រយោជន៍លើមរណភាព

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ក្រុមហ៊ុននឹងផ្តល់សំណង លើ**អត្ថប្រយោជន៍លើមរណភាព**ស្មើនឹង 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន បន្ទាប់មកមិនតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគត សម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានទៀតឡើយ។

## អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ក្រុមហ៊ុន នឹងផ្តល់សំណងលើ **អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**ស្មើនឹង 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន
បន្ទាប់មកមិនតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគត លើផលិតផលធានារ៉ាប់រងមូលដ្ឋានទៀតឡើយ។

## អត្ថប្រយោជន៍លើការសិក្សា

### 1. អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា

**អត្ថប្រយោជន៍លើការសិក្សាដែលត្រូវបានធានា** សម្រាប់កូនរបស់អ្នកក្នុងការបន្តសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា បើទោះជាមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងក៏ដោយ។

- ទទួលទឹកប្រាក់សរុបស្មើនឹង 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន ឬ
- ទទួលទឹកប្រាក់ជា 4 ដំណាក់កាលស្មើនឹង 105% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន។

### 2. អត្ថប្រយោជន៍បន្ថែមលើការសិក្សា

**អត្ថប្រយោជន៍បន្ថែមលើការសិក្សា** 100% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន សម្រាប់ជម្រើសការទទួលទឹកប្រាក់សរុប ឬ 105% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន សម្រាប់ជម្រើសទទួលទឹកប្រាក់ជាដំណាក់កាល ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ មុនពេលទទួលបានការទូទាត់អត្ថប្រយោជន៍លើការសិក្សា។

* អត្ថប្រយោជន៍បន្ថែមលើការសិក្សា នឹងអាចអនុវត្តបានតែចំពោះម្ចាស់បណ្ណសន្យារ៉ាប់រងចាប់ពីអាយុ 18 ឆ្នាំឡើងខណៈពេលចុះឈ្មោះដំបូង។

## អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា

**អត្ថប្រយោជន៍លើការបញ្ចប់ការសិក្សា** គឺជាការអបអរសាទរលើភាពជោគជ័យសម្រាប់ការ បញ្ចប់ការសិក្សា តាមកម្រិតនីមួយៗរបស់កូនអ្នក ជាមួយអត្ថប្រយោជន៍ដែលទទួលបានស្មើនឹង 10% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន ។

**រយៈពេលនៃការធានារ៉ាប់រង**

15 ដល់ 22 ឆ្នាំ

**រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង**

5 ឆ្នាំ 10 ឆ្នាំ 15 ឆ្នាំ 18 ឆ្នាំ

**អាយុចុះឈ្មោះដំបូង**

30 ថ្ងៃ ដល់ 60 ឆ្នាំ

**ការទាមទារសំណង**

ប្រសិនបើអ្នកចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងកំឡុងពេល 90 ថ្ងៃពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ អ្នកអាចទាញយកទម្រង់បែបបទទាមទារសំណង ពីគេហទំព័ររបស់យើង គឺ aia.com.kh ឬ ពីទីប្រឹក្សាផែន
ការជីវិត AIA។

**ការទទួលយកសំណើធានារ៉ាប់រង**

សូមទាក់ទងទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care service តាមរយៈ ទូរស័ព្ទលេខ 086 999 242 ឬ អ៊ីមែលមកកាន់ KH.Care@aia.com ឬ ចូលទៅកាន់គេហទំព័រ aia.com.kh ។

## 1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព

ការទទួលខុសត្រូវរបស់ក្រុមហ៊ុន មានកំណត់ត្រឹមតម្លៃសាច់ប្រាក់ពេលបោះបង់បណ្ណសន្យារ៉ាប់រង ដកបំណុលដែលមានក្នុងបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពដោយសារៈ

(i) ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាន ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(ii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(iii) វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(iv) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## 2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ក្រុមហ៊ុននឹងមិនធានាលើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះៈ

(i) ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

(ii) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្រ្គាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ

(iii) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(iv) ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ

(v) ការប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ ប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(vi) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## 3. ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ

(i) ក្រុមហ៊ុនអាចលុបចោលបណ្ណសន្យារ៉ាប់រងនេះនៅពេលណាមួយក៏បាន (ដោយការលុបចោលសុពលភាពគិតចាប់ពីកាលបរិច្ឆេទ ចេញបណ្ណសន្យារ៉ាប់រង ឬផ្សេងពីនេះ) តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពណាមួយដែលពាក់ព័ន្ធនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ តាមការយល់ឃើញរបស់ក្រុមហ៊ុន ត្រូវបានរកឃើញថាបានបង្ក ឬអាចនឹងបង្កហានិភ័យផ្នែកទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងមកដល់ក្រុមហ៊ុនតាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬតាមការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្រុមហ៊ុននឹងមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយម្ចាស់បណ្ណសន្យារ៉ាប់រងពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះនោះទេ ដោយរួមបញ្ចូលទាំង និងមិនកំណត់ត្រឹមតែការផ្តល់ ឬទទួលទូទាត់ទឹកប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។

(ii) ដោយមិនមានការប៉ះពាល់ដល់សុពលភាពកថាខណ្ឌ (i) ខាងលើនៃប្រការនេះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថា មិនត្រូវផ្តល់ការធានាណាមួយឡើយ ហើយក្រុមហ៊ុនក៏មិនទទួលខុសត្រូវក្នុងការទូទាត់សំណង ឬផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្នុងទំហំដែលការផ្តល់ការការពារ ការទូទាត់សំណង ឬការផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗទាំងនោះ អាចនាំឱ្យក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនានាពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។

(iii) ជាកាតព្វកិច្ចដែលត្រូវអនុវត្តបន្តជាប្រចាំ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រុមហ៊ុន ប្រសិនបើមានករណីផ្លាស់ប្តូរអត្តសញ្ញាណស្ថានភាព (មុខដំណែង) លក្ខន្តិកៈ (ក្នុងករណីជាក្រុមហ៊ុន) ក្រុមហ៊ុនពាក់ព័ន្ធនឹងម្ចាស់បណ្ណសន្យារ៉ាប់រងក្រោមខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងនេះ ព័ត៌មានលម្អិត និងឯកសារអត្តសញ្ញាណកម្មរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពនានាដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះ។

## បន្ថែមការការពារលើគម្រោងធានារ៉ាប់រង AIA សម្រាប់កូន ជាមួយជម្រើស

# ផលិតផលធានារ៉ាប់រងបន្ថែម

### ផលិតផលធានារ៉ាប់រងបន្ថែមលើប្រាក់ឧបត្ថម្ភគ្រួសារ

**ការការពារបន្ថែមលើការបាត់បង់ចំណូលប្រចាំគ្រួសារ**

ការការពារបន្ថែមដើម្បីធានាថាកូនរបស់អ្នក ឬគ្រួសាររបស់អ្នក នឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមប្រចាំឆ្នាំប្រសិនបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើង។

### ផលិតផលធានារ៉ាប់រងបន្ថែមលើមរណភាព ពិការភាព និងការរលាកដោយគ្រោះថ្នាក់ចៃដន្យ

**ការការពារបន្ថែមលើព្រឹត្តិការណ៍អកុសលដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ**

បង្កើនកម្រិតការការពាររបស់អ្នក ដើម្បីធានាថាអ្នក និងមនុស្សស្រឡាញ់របស់អ្នក នឹងទទួលបានការការពារផ្នែកហិរញ្ញវត្ថុ ប្រសិនបើអ្នកជួបប្រទះនូវព្រឹត្តិការណ៍អកុសលណាមួយដោយចៃដន្យ។

### ផលិតផលធានារ៉ាប់រងបន្ថែមលើចំណាយសម្រាកក្នុងមន្ទីរពេទ្យដោយសារគ្រោះថ្នាក់ចៃដន្យ

**ការការពារពីការរងរបួសដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ**

ផ្តល់ជូនអ្នកនូវទឹកប្រាក់សំណងជាប្រចាំថ្ងៃ ដើម្បីជំនួសការបាត់បង់ប្រាក់ចំណូលរបស់អ្នក ក្នុងករណីតម្រូវឱ្យមានការចូលសម្រាកក្នុងមន្ទីរពេទ្យដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ។

### ផលិតផលធានារ៉ាប់រងបន្ថែមលើការលើកលែងការបង់បុព្វលាភធានារ៉ាប់រងផ្លាស់

**ការការពារពីការមិនអាចបន្តបង់បុព្វលាភធានារ៉ាប់រងដោយអចេតនា**

លើកលែងរាល់បុព្វលាភធានារ៉ាប់រងដែលនៅសល់នាពេលអនាគតរបស់អ្នក ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬមានជំងឺ/ការរះកាត់ធ្ងន់ធ្ងរ ដូចដែលបានកំណត់ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ក្នុងកំឡុងពេលនៃការធានារ៉ាប់រង។

### ផលិតផលធានារ៉ាប់រងបន្ថែមលើការលើកលែងការបង់បុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរ

**ការការពារពីការមិនអាចបន្តបង់បុព្វលាភធានារ៉ាប់រងដោយអចេតនា**

លើកលែងរាល់បុព្វលាភធានារ៉ាប់រងដែលនៅសល់នាពេលអនាគតរបស់អ្នកប្រសិនបើអ្នកមានជំងឺ/ការរះកាត់ធ្ងន់ធ្ងរដូចដែលបានកំណត់ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ក្នុងកំឡុងពេលនៃការធានារ៉ាប់រង។

### ផលិតផលធានារ៉ាប់រងបន្ថែមលើជំងឺធ្ងន់ធ្ងរ

**ការការពារបន្ថែមលើជំងឺធ្ងន់ធ្ងរ**

ផ្តល់ជូនអ្នកនូវកញ្ចប់ទឹកប្រាក់ធានារ៉ាប់រង នៅពេលអ្នកធ្វើរោគវិនិច្ឆ័យឃើញថាមានស្ថានភាពជំងឺណាមួយនៃ 26 ប្រភេទនៃជំងឺមហារីក ជំងឺខួរក្បាល ជំងឺថ្លើម ជំងឺសួត ជំងឺតម្រងនោម ជំងឺបេះដូង និងប្រព័ន្ធសរសៃឈាម ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ ព្រមទាំងការផ្លាស់ប្តូរសរីរាង្គសំខាន់ៗផងដែរ។ ជាមួយនឹងទឹកប្រាក់ដែលនឹងបង់ជូន រហូតដល់ 50% សម្រាប់ជំងឺដំណាក់កាលដំបូង អ្វីដែលអ្នកផ្តោតសំខាន់នោះ គឺការមើលថែទាំខ្លួនឲ្យបានឆាប់ជាសះស្បើយ ជាជាងព្រួយបារម្ភអំពីការចំណាយទៅលើការព្យាបាលរបស់អ្នក។

**ការិយាល័យកណ្តាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA